ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៨៧២.....សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារចម្រុះ សម្រាប់ការរៀបចំ និងវាយតម្លៃការអនុវត្តប្រកាសរួម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារចម្រុះ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ អង្គភាពប្រឆាំងអំពើពុករលួយ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដូចមានរាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **ជូ គីមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **យក់ ម៉ុនណា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៣- ឯកឧត្តម **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **យន់ ស៊ីណាត** | ឧបការីអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ៥- ឯកឧត្តម **សម្បត្តិ ហ៊ូណា** | ឧបការីអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |
| ៦- ឯកឧត្តម **ខិន សុឃួន** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៧- លោកជំទាវ **ឈី វិជ្ជរ៉ា** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨- ឯកឧត្តម **គង់ សុគី** | អគ្គនាយក នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩- ឯកឧត្តម **ឆាន់ ចណ្ណី** | អគ្គាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០- លោក **អួន ម៉ុនហាក់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក សហវ | សមាជិក |
| ១១- លោក **ម៉ុញ្ញ បានសុវណ្ណអានិច្ចសីលា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរតនាគារជាតិនៃ ក សហវ | សមាជិក |
| ១២- លោក **នួច សុខសម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា នៃ ក សហវ | សមាជិក |
| ១៣- លោក **ចន ណារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃ ក សហវ | សមាជិក |
| ១៤- លោក **ច្រាក់ ម៉ុច** | អគ្គនាយករង នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៥- លោក **ឈុន សុជាតិ** | អគ្គនាយករង នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៦- លោក **សុត ឆា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រតិបត្តិការ នៃ អ.ប.ព | សមាជិក |
| ១៧- លោក **ហែម មគ្គផល** | អគ្គាធិការរង នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៨- លោក **ម៉ៅ ចុញ្ញខេត្ត** | ប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃ ក សហវ | សមាជិក |
| ១៩- លោក **សយ រាសី** | ប្រធាននាយកដ្ឋាន នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២០- លោកស្រី **ម៉ា សូយ៉ិនដា** | ប្រធាននាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នៃ អ.ប.ព | សមាជិក |

| | | |
|---|---|---|
| ២១-លោក **ឆេព ទណ្ណដា** | អនុប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃ ក សហវ | សមាជិក |
| ២២-លោក **ផាត ពិសី** | អនុប្រធាននាយកដ្ឋានចំណូលសាធារណៈ នៃ ក សហវ | សមាជិក |
| ២៣-កញ្ញា **ឈុន ដាលីន** | អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃ ក សហវ | សមាជិក |
| ២៤-លោកស្រី **នង សុគន្ធាទី** | អនុប្រធាននាយកដ្ឋានស៊ើបអង្កេត និងចារកម្ម នៃ អ.ប.ព | សមាជិក |
| ២៥-លោក **ញ៉ៀម ចូរ៉ា** | អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ នៃ អ.ប.ព | សមាជិក |
| ២៦-លោកស្រី **អ៊ូ ស៊ីថា** | អនុប្រធាននាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នៃ អ.ប.ព | សមាជិក |
| ២៧-លោកស្រី **កែម សុគន្ធា** | អនុប្រធាននាយកដ្ឋានប្រកាសទ្រព្យសម្បត្តិវដ្ត និងបំណុល នៃ អ.ប.ព | សមាជិក |
| ២៨-លោក **ហ៊ត់ ធានី** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានចំណូលសាធារណៈ នៃ ក សហវ | សមាជិក |
| ២៩-លោក **ហោ សុទ្ធុន្នី** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានចំណូលសាធារណៈ នៃ ក សហវ | សមាជិក |

**ប្រការ២ .-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

- វាយតម្លៃលើការអនុវត្តប្រកាសរួម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ អាចស្នើឱ្យមានការចូលរួមពីសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផងដែរ។
- ពិនិត្យ និងលើកអនុសាសន៍កែលម្អក្របខ័ណ្ឌស្តង់ដារសេវាសាធារណៈ និងយន្តការនៃការប្រមូលចំណូល ក៏ដូចជាគោលការណ៍ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួង ស្ថាប័ន
- សិក្សាអំពីលទ្ធភាពជ្រើសរើសក្រុមហ៊ុនឯកជន ឬ ដាក់ស្ថាប័នរដ្ឋទាំងឡាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ សហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដើម្បីបំពេញមុខងារជាទីភ្នាក់ងារផ្តល់សេវាសាធារណៈ ដោយលើកអនុសាសន៍ ស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- ស្នើឡើងនូវវិធានការលើកទឹកចិត្ត ឬ រឹតត្បិតចំណាយថវិកាប្រចាំឆ្នាំ ឬ បន្ថយអត្រាប្រាក់រង្វាន់ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តចំណូល និងការអនុវត្តស្តង់ដារសេវាសាធារណៈរបស់សាមីក្រសួង ស្ថាប័ន
- ប្រជុំមួយឆមាសម្តង ក្នុងក្របខ័ណ្ឌក្រុមការងារ និងប្រជុំវិសាមញ្ញតាមការចាំបាច់ និងធ្វើរបាយការណ៍ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីលទ្ធផលនៃការអនុវត្តប្រកាសរួម ស្តីពីការផ្តល់សេវាសាធារណៈ និងវាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តកម្រៃសេវាសាធារណៈទៅលើកម្រិតជីវភាពប្រជាជន និងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយប្រទេសជិតខាងក្នុងតំបន់ ដោយអនុលោមទៅនឹងស្តង់ដារសេវាសាធារណៈ ដែលកំពុងអនុវត្ត ដើម្បីមានមូលដ្ឋានលើកឡើងនូវវិធានការកែសម្រួលកម្រៃសេវាសាធារណៈរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យបានសមស្រប និងគោរពស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .-**

ប្រកាសលេខ ៨០៨ សហវ.ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារចម្រុះនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពប្រឆាំងអំពើពុករលួយ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សម្រាប់ពិនិត្យប្រាក់សម្រួលការងារ (កម្រៃសេវា) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមនិវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ